សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ១១៦ "ភ"

ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០

-សំណុំរឿងរដ្ឋប្បវេណីលេខ ១០៨៩

ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៩ និង០០នាទីព្រឹក និងប្រកាសសាលក្រមនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១០៨៩ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ [redacted] **គា** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះ [redacted]។

តំណាងដោយអាណត្តិដើមចោទលោកមេធាវី [redacted] អត្តលេខ ១៦៦៨T។

-ចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន [redacted]

## I.អង្គហេតុ និងចំណុចវិវាទ

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖**

-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** សងប្រាក់មកឲ្យដើមបណ្តឹងឈ្មោះ [redacted] **គា** ចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក។

-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** សងការប្រាក់តាមផ្លូវច្បាប់កំណត់ លើចំនួនប្រាក់ជំពាក់សរុប ៤,០០០ (បួនពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៨-៦-២០១៦ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន មកឲ្យដើមបណ្តឹង។

-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** សងជម្ងឺចិត្ត និងថ្លៃសេវាកម្មផ្នែកច្បាប់ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ ចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** បានចុះកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ ជាមួយនឹងដើមចោទឈ្មោះ [redacted] **គា** ទៅលើប្រាក់កម្ចីចំនួន ៤,០០០$ (បួនពាន់)ដុល្លារអាមេរិក ដោយគិតការប្រាក់ចំនួន ២០០$ (ពីររយ)ដុល្លាអាមេរិក ក្នុងមួយខែ ដោយសន្យាសងវិញក្នុងរយៈពេល៣ខែ គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦។ ជាក់ស្តែងចុងចម្លើយមិនដែលបានប្រគល់ប្រាក់ថ្លៃជំពាក់ប្រាក់ដើម រួមទាំងការប្រាក់មកអោយដើមចោទម្តងណាឡើយ ចាប់តាំងពីថ្ងៃចុះកិច្ចសន្យាខ្ចី



Scanned with CamScanner

ប្រាក់រួចមក ចុងចម្លើយមិនអនុវត្តតាមខ្លឹមសារដែលមានចែងក្នុងលិខិតកិច្ចសន្យាខ្ចីប្រាក់នោះទេ ដោយមានបំណងគេចវេសមិនចង់សងនូវប្រាក់ដែលបានខ្ចីពីដើមចោទ។

**៣.អង្គហេតុដែលអះអាងដោយដើមចោទ៖**

មេធាវី [redacted] តំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា៖ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ខ្លួនសុំរក្សានូវសេចក្តីថ្លែងការណ៍នៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទាំងអស់ និងខ្លឹមសារនៃពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ទុកជាបានការទាំងស្រុង។ កូនក្តីខ្លួននៅតែប្រកាន់ជំហរប្តឹងទាមទារឱ្យចុងចម្លើយសងប្រាក់ចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក ដោយសំអាងលើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ ដោយមានការយល់ព្រមបង់ការប្រាក់ ចំនួន ២០០ (ពីររយ)ដុល្លារអាមេរិក ក្នុងមួយខែ តែពេលនេះសុំឱ្យតុលាការសម្រេចអំពីការប្រាក់តាមច្បាប់។ ដោយកូនក្តីខ្ញុំបាទខូចប្រយោជន៍ជាច្រើន ដូចនេះទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត និងថ្លៃសេវាកម្មផ្នែកច្បាប់ចំនួន ៣,០០០(បីពាន់) ដុល្លារអាមេរិក ចំពោះការទាមទារឱ្យកូនក្តីខ្ញុំបាទមានការស្បថស្បែរ កូនក្តីខ្លួនបានព្យាយាមទាក់ទងទៅចុងចម្លើយដើម្បីបំពេញតម្រូវរបស់ចុងចម្លើយរួចហើយ តែចុងចម្លើយបានព្យាយាមបង្កការលំបាក ដែលជាហេតុមិនអាចឱ្យកូនក្តីខ្លួនធ្វើការស្បថស្បែរបាន ដូចនេះខ្លួនសុំបដិសេធចំពោះការទាមទារឱ្យធ្វើការស្បថស្បែរនេះ។

**៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ៖**

ចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** បានថ្លែងការណ៍ថា ខ្ញុំបាទសុំបដិសេធចំពោះការទាមទារប្រាក់ចំនួន ៤,០០០(បួនពាន់)ដុល្លារអាមេរិក របស់ដើមចោទ ដោយហេតុថា ប្រាក់ដែលដើមចោទទាមទារនោះគឺជាប្រាក់ដែលខាតបង់ក្នុងការរកស៊ីជុំគ្នា ហើយចំពោះកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ ខ្ញុំសុំមិនទទួលស្គាល់ទេ។ តែបើដើមចោទហ៊ានស្បថចំពោះមុខវត្ថុស័ក្តសិទ្ធ ថាបានប្រគល់លុយឱ្យមកខ្លួនចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក មែន ខ្ញុំយល់ព្រមសងប្រាក់ចំនួន ៤,០០០(បួនពាន់)ដុល្លារអាមេរិក ឱ្យដើមចោទវិញ។

**៥.ចំណុចមានវិវាទ៖**

តើចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន ៤,០០០(បួនពាន់)ដុល្លារអាមេរិក ដែរឬទេ?

**៦.ចំណុចគ្មានវិវាទ៖** មាន។

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសារ៖**

១.១.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦។

១.២.លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ និងលិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ រវាងដើមចោទ និងចុងចម្លើយ ឃើញថាចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** ពិតជាបានចុះកិច្ចសន្យាខ្ចីប្រាក់ ចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក ពីដើមចោទឈ្មោះ [redacted]តា ប្រាកដមែន។

២-ចំពោះការទាមទាររបស់ដើមចោទ សុំឱ្យចុងចម្លើយសងប្រាក់ដើម ចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក ដោយសំអាងលើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ មានលក្ខណៈត្រឹមត្រូវតាមភស្តុតាងជាក់ស្តែងដែលបានដាក់មកឱ្យតុលាការពិនិត្យ។ ដូចនេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។



Scanned with CamScanner

៣-ចំពោះការទាមទាររបស់ដើមចោទ សុំឲ្យចុងចម្លើយបង់ការប្រាក់តាមផ្លូវច្បាប់កំណត់ លើចំនួនប្រាក់ជំពាក់សរុបចំនួន ៤,០០០(បួនពាន់)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។ ដូចនេះគប្បីតុលាការពិចារណា លើស្ថានភាពរបស់ចុងចម្លើយនាពេលបច្ចុប្បន្ន និងអត្រាការប្រាក់គិតចាប់ពីថ្ងៃដែលខកខានមិនបានបង់ការប្រាក់ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹង ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩។

៤-ដើមចោទ បានទាមទារឲ្យចុងចម្លើយសងជម្ងឺចិត្ត និងសេវាកម្មផ្នែកច្បាប់ សរុបចំនួន ៣,០០០(បីពាន់)ដុល្លារអាមេរិក ដោយហេតុថាចុងចម្លើយមិនអនុវត្តតាមកាតព្វកិច្ចនៃកិច្ចសន្យាខ្ចីប្រាក់ ដែលធ្វើឲ្យដើមចោទខូចប្រយោជន៍ជាច្រើន។ ឃើញថាការទាមទារនេះមានចំនួនច្រើនលើសលប់ ដូចនេះគប្បីតុលាការពិចារណាទៅតាមស្ថានភាពជាក់ស្ដែង។

៥-ចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** ភេទប្រុស អាយុ២៦ឆ្នាំ តុលាការបានធ្វើការបញ្ជូនដីកាកោះឲ្យចូលរួមការទាញហេតុផលដោយផ្ទាល់មាត់ ត្រឹមត្រូវតាមច្បាប់ តែចុងចម្លើយនៅតែអវត្តមានដោយគ្មានមូលហេតុ ដូចនេះចាត់ទុកថាចុងចម្លើយទទួលស្គាល់សេចក្ដីថ្លែងការណ៍ទាមទាររបស់ដើមចោទ យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៦-ប្រាក់ប្រាប់ក្ដីគប្បីសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្ដីសម្រេចបញ្ចប់**

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ច័ន្ទមាន** ភេទប្រុស កើតថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៩៣ ជនជាតិខ្មែរ សង៖

ក.ប្រាក់ដើម ចំនួន ៤,០០០ (បួនពាន់)ដុល្លារអាមេរិក។

ខ.ការប្រាក់ចំនួន **១,៥%** ក្នុងមួយខែ លើប្រាក់ដើមចំនួន ៤,០០០ (បួនពាន់)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩។

គ.សំណងជម្ងឺចិត្ត និងសេវាកម្មផ្នែកច្បាប់ ចំនួន **២,០០០,០០០៛ (ពីរលាន)រៀល**។ ការទាមទារលើសពីនេះច្រានចោល។

ទៅឲ្យដើមចោទឈ្មោះ [redacted]**តា** ភេទប្រុស កើតថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨៩ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ១៥៧ ផ្លូវលេខ៣៣០ ភូមិ០២ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ចំពោះមុខតំណាងដោយអាណត្តិឲ្យដើមចោទ កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០

**បានឃើញ**
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner